សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMERS KAMPUCHEA-KROM FEDERATION

P. O . Box 0193. Pennsauken, NJ 08110. (U.S.A.) Tel: (267) 240 - 5603
http://www.khmerkrom.net / www.khmerkrom.org

# អបអរសាទរទិវានារីអន្តរជាតិ ៨ មីនា

**ថ្ងៃ ៨ មីនា** ជាទិវានារីអន្តរជាតិ ខួប ១១០ ឆ្នាំ (៨ មីនា ឆ្នាំ ១៨៩៩ - **៨ មីនា ឆ្នាំ ២០២១**) ដែលស្ត្រី នៅជុំវិញពិភពលោក បានរៀបចំពិធីអបអរសាទរ ៨ មីនា ដើម្បីរំលឹកឡើងនូវប្រវត្តិនៃតស៊ូរបស់ស្ត្រីក្នុងការក្រោកឈរទាមទារសិទ្ធិសេរីភាពរបស់ខ្លួន ដែលត្រូវបានថៅកែ ម្ចាស់រោងចក្រ, ក្រុមហ៊ុន, អ្នកមានអំណាច និង ប្រទេសផ្តាច់ការ រំលោភបំពាន គៀបសង្កត់ កេងប្រវ័ញ្ច ពីកម្លាំងស្ត្រីហួសប្រមាណ ។

**ថ្ងៃ ៨ មីនា** ជារៀងរាល់ឆ្នាំ ស្ត្រីខ្មែរក្រោម នៃសហព័ន្ធខ្មែរកម្ពុជាក្រោម បានរៀបចំអបអរសាទរទិវានារីអន្តរជាតិ នៅទីក្រុងភីឡាដាផ្យា រដ្ឋផែនស៊ីវិញ៉ា សហរដ្ឋអាមេរិក មិនដែលខកខានឡើយ ដើម្បីរំលឹកនូវសកម្មភាព នៃការតស៊ូរបស់ស្ត្រីខ្មែរក្រោម លើឆាកអន្តរជាតិ និងជួបជុំបងប្អូនជនរួមជាតិ ពិសារអាហារសាមគ្គីជាមិត្តភាពផងដែរ ប៉ុន្តែសម្រាប់ឆ្នាំ ២០២០ និង ២០២១ នេះ ស្ត្រីខ្មែរក្រោម នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ខកខានមិនបានរៀបចំទិវាអបអរសាទរ ៨ មីនា ដូចឆ្នាំមុនៗ ទេ ដោយសារករណី កូវីដ ១៩ ។

**ថ្ងៃ ៨ មីនា** ស្ត្រីខ្មែរក្រោមរាប់លាននាក់ នៅលើដែនដីកម្ពុជាក្រោម ស្ថិតក្រោមនឹមអាណានិគមយួន មិនបានរៀបចំអបអរសាទរទិវានារីអន្តរជាតិ ដូចស្ត្រីនៅជុំវិញពិភពលោក និងស្ត្រីខ្មែរក្រោម នៅក្រៅប្រទេសឡើយ គឺរដ្ឋាភិបាលកុម្មុយនីស្តវៀតណាម មិនអនុញ្ញាតិឱ្យស្ត្រីខ្មែរក្រោម ឬ ពលរដ្ឋខ្មែរក្រោម រៀបចំពិធីជាប្រវត្តិសាស្ត្រមួយនេះ នៅដែនដីកម្ពុជាក្រោមឡើយ ។

**ថ្ងៃ ៨ មីនា** ស្ត្រីខ្មែរក្រោម កំពុងរស់នៅក្រោមនឹមអាណានិគមយួនបច្ចុប្បន្ន ដោយគ្មានសិទ្ធិសេរីភាព, គ្មានយុត្តិធម៌ និង ត្រូវបានរើសអើងពូជសាសន៍ពីរដ្ឋាភិបាលវៀតណាម ។

**ថ្មីៗ នេះ** ពលរដ្ឋខ្មែរក្រោម បានបោះពុម្ពអាវយឺត មានអក្សរថា **ខ្មែរក្រោមអបអរទិវានារីអន្តរជាតិ** ត្រូវបានអាជ្ញាធរយួន នៅស្រុកកំពង់ស្ពាន ខែត្រព្រះត្រពាំង ចុះទៅរឹបអូសយកទាំងស្រុង និងគំរាមគំហែងហាមម្ចាស់ផ្ទះ អ្នកស៊ីឈ្នួលបោះពុម្ពអាវយឺត មិនឱ្យបោះពុម្ពតទៅទៀត និង ចេញលិខិតកោះហៅទៅសួរចម្លើយផងដែរ ។

**មាត្រា ២២** នៃច្បាប់ជនជាតិដើម រដ្ឋអំណាចត្រូវយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិ និង សេចក្តីត្រូវការពិសេសរបស់ជនជាតិដើម ដែលជាមនុស្សចាស់ ស្ត្រី យុវជន កុមារ ជនពិការ និងមិនរើសអើងគ្រប់រូបភាព ។

**ប្រធានស្ត្រី នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម** សូមចូលរួមអបអរសាទរខួប ១១០ ឆ្នាំ ទិវានារីអន្តរជាតិ ៨ មីនា និងសូមថ្កោលទោសដាច់អហង្ការចំពោះទង្វើរំលោភសិទ្ធិ និង រើសអើង លើស្ត្រីខ្មែរក្រោម ពីសំណាក់រដ្ឋាភិបាលវៀតណាម ជាពិសេសនាងខ្ញុំ សូមអំពាវនាវដល់រដ្ឋាភិបាលវៀតណាម ត្រូវតែគោរពសិទ្ធិមនុស្សជាមូលដ្ឋានចំពោះស្ត្រី និងពលរដ្ឋខ្មែរក្រោម ដែលជាម្ចាស់ស្រុកជនជាតិដើម នៅដែនដីកម្ពុជាក្រោម ។

សហរដ្ឋអាមេរិក, ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០២១

**អ្នកស្រី ស៊ឺន ធី និត**

ប្រធានស្ត្រីខ្មែរក្រោម នៃសហព័ន្ធខ្មែរកម្ពុជាក្រោម